សូមគោរពមាតាបិតា/អាណាព្យាបាលៈ

ខ្ញុំសរសេរលិខិតមកជំរាបជូនថា កូនសិស្សរបស់រដ្ឋ Massachusetts ទាំងអស់ ត្រូវតែបំពេញទៅតាមស្តង់ដារ ដែលមាន រៀបរាប់ក្នុងទំរង់បែបបទដែលបានភ្ជាប់មកជាមួយ ដែលជាតំរូវការបន្ថែមលើល័ក្ខខ័ណ្ឌទាំងឡាយសំរាប់ការបញ្ចប់ ការសិក្សានៅក្នុងតំបន់ ដើម្បីទទួលបានសញ្ញាប័ត្រសាលាសិក្សាជាន់ខ្ពស់ ។

កូនប្រុស ឬកូនស្រីរបស់លោកអ្នក មិនទាន់បំពេញបាននូវល័ក្ខខ័ណ្ឌទាំងឡាយដូចខាងក្រោម សំរាប់ការបញ្ចប់ការ សិក្សានៅឡើយទេៈ

________________________________________________________________ ។

ឱកាសបន្ទាប់ដើម្បីចូលរួមក្នុងការប្រលងរបស់ MCAS គឺៈ

________________________________________________________________ ។

កូនសិស្សអាចចូលរួមក្នុងការប្រលងបានច្រើនដងតាមតំរូវការ ទាំងពេលនៅក្នុងសាលាសិក្សាជាន់ខ្ពស់ និងក្រោយពី នេះ ។ ខ្ញុំសូមជំរុញលើកទឹកចិត្តជាខ្លាំងចំពោះកូនសិស្ស ដែលមិនទាន់បានបំពេញនូវល័ក្ខខ័ណ្ឌទាំងឡាយរបស់រដ្ឋ សំរាប់ ការបញ្ចប់ការសិក្សា អោយចូលរួមនៅក្នុងឱកាសប្រលងបន្ទាប់ ។ ក្នុងករណីដែលកូនរបស់លោកអ្នកសំរេចចិត្តមិន ចូលរួមក្នុងឱកាសប្រលងនេះ សូមបំពេញ និងចុះហត្ថលេខាលើទំរង់បែបបទសំរាប់អ្នកដែលមិនបានចូលរួមក្នុង MCAS ដែលបានភ្ជាប់មកជាមួយនេះ រួចផ្ញើរត្រលប់មកខ្ញុំវិញ ។

ខ្ញុំក៏ចង់ជំរាបជូនលោកអ្នកផងដែរថា សាលារបស់យើងខ្ញុំបានបង្កើតនូវកម្មវិធីគាំទ្រការសិក្សា ដើម្បីជួយកូនសិស្ស ត្រៀមសំរាប់ការប្រលង ។ ពតិមានអំពីកម្មវិធីទាំងនេះ មាននៅ ______________________ ។

ជាសេចក្តីបន្ថែម ខ្ញុំក៏ចង់ជំរាបជូនលោកអ្នកផងដែរថា កូនសិស្សអាចតំរូវអោយបំពេញទៅតាមល័ក្ខខ័ណ្ឌនៃការ ប្រលងរបស់រដ្ឋ តាមរយៈដំណើរការបង្ហាញស្នាដៃរបស់ MCAS ដែលបានគ្រោងឡើងសំរាប់អោយកូនសិស្សបង្ហាញ តាមរយៈវគ្គសិក្សារបស់ពួកគេថា ពួកគេបានបំពេញតាម ឬបានលើសស្តង់ដាដែលកំណត់អោយជាប់ ទោះបីជាគេមិន អាចបង្ហាញបានតាមរយៈការប្រលងរបស់ MCAS ជាច្រើនដងក៏ដោយ ។

ប្រសិនបើលោកអ្នកមានសំណួរពាក់ព័ន្ធនឹងឱកាសនៃការប្រលងនេះ ឬមានមតិយោបល់ផ្សេងៗ សូមទាក់ទង

នាយកដ្ឋានអាណាព្យាបាលរបស់សាលា ឬការិយាល័យរបស់ខ្ញុំ ។ ខាងក្រោមនេះ គឺជាពត៌មានទំនាក់ទំនងរបស់យើងខ្ញុំ:

- ឈ្មោះបុគ្គលទំនាក់ទំនង និងតួនាទី: __________________________________________
- ទូរស័ព្ទ: ______________________________________________
- អ៊ីមែល: ________________________________________________

ខ្ញុំជឿជាក់ថា ការចូលរួមរបស់យើងទាំងអស់គ្នាអាចជួយកូនសិស្សទាំងអស់អោយទទួលបានជោគជ័យ ។ សូមថ្លែងអំណរគុណចំពោះការសហការ ។

ដោយសេចក្តីគោរព

__________________________

នាយកសាលា